Fortune
LIFE INSURANCE



*Here for you,*
*for life*



# ផលិតផល
# ការសិក្សា
# ជាមួយ ហ្វ័រឈូន ឡាយហ្វ៍




Fortune Life Insurance PLC fortunelifecambodia
www.fortunelife.com.kh +855 23 931 999 | 1800-202 202 ឥតគិតថ្លៃ
អគារឌឹហ្គេតវេយ៍ ជាន់ទី26 មហាវិថីសហព័ន្ធរុស្សី (ផ្លូវ110) សង្កាត់ផ្សារដេប៉ូទី3
ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



# ផលិតផលការសិក្សា

## ជាមួយ ហ្វ៊ីឈូន ឡាយហ្វ៍

គឺជាផលិតផលដ៏អស្ចារ្យ ដែលធានាដល់ការសិក្សារបស់កូនៗ ដោយលោកអ្នកមិនចាំបាច់បារម្ភពីការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ។

ផលិតផលការសិក្សាជាមួយ ហ្វ៊ីឈូន ឡាយហ្វ៍ គឺជាផលិតផលធានារ៉ាប់រងអាយុជីវិតដែលផ្តល់នូវការការពារទៅលើការសន្សំសម្រាប់ការសិក្សា។

## សារៈសំខាន់

- ផ្តល់ជូននូវអត្ថប្រយោជន៍ការសិក្សាដែលត្រូវបានធានារហូតដល់ ១១០% នៃចំនួនទឹកប្រាក់ធានារ៉ាប់រង សម្រាប់ការសិក្សាថ្នាក់វិទ្យាល័យ ឬ សាកលវិទ្យាល័យ។
- ផ្តល់ជូនការការពារ ទាំងអ្នកត្រូវបានធានារ៉ាប់រង និង អ្នកបង់ប្រាក់ក្នុងពេលបណ្ណសន្យារ៉ាប់រងមានសុពលភាព ដោយបង់បុព្វលាភធានារ៉ាប់រងដែលមានតម្លៃសមរម្យ។
- ផ្តល់ជូនអត្ថប្រយោជន៍លើកលែងការបង់បុព្វលាភធានារ៉ាប់រងនាពេលអនាគតក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬករណីជំងឺធ្ងន់ធ្ងររបស់អ្នកបង់ប្រាក់។

១០០% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងនឹងត្រូវបង់ជូនក្នុងករណីអ្នកត្រូវបានធានារ៉ាប់រង ទទួលមរណភាព /ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

អត្ថប្រយោជន៍ការសិក្សាដែលត្រូវបានធានាចំនួន ១១០% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងសម្រាប់អំឡុងពេលសិក្សា

អាចបន្ថែមអត្ថប្រយោជន៍ការពារផ្សេងទៀតសម្រាប់អ្នកបង់ប្រាក់

ផ្តល់ជូនជម្រើសសំខាន់ៗចំនួន២គឺជម្រើសវិទ្យាល័យ និង ជម្រើសសាកលវិទ្យាល័យ

លោកអ្នកអាចជ្រើសរើសការបង់បុព្វលាភធានារ៉ាប់រងជាប្រចាំឆមាស ឬប្រចាំឆ្នាំ។

## ដំណើរការរបស់ផលិតផល

លោក ដារ៉ា អាយុ ៣៥ ឆ្នាំ បានទិញផលិតផលការសិក្សាជាមួយ ហ្វ៊ីឈូន ឡាយហ្វ៍ (ជម្រើស សាកលវិទ្យាល័យ) សម្រាប់កូនប្រុសអាយុ ៩ ឆ្នាំរបស់គាត់ ដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងចំនួន $១០,០០០។ លោក ដារ៉ា បានបង់បុព្វលាភប្រចាំឆ្នាំចំនួន $៩៣៩.២ ដើម្បីទិញផលិតផលនេះ នឹងទទួលនូវការការពារទៅលើអត្ថប្រយោជន៍ដូចខាងក្រោម៖



| អត្ថប្រយោជន៍ធានារ៉ាប់រង | ទឹកប្រាក់ធានារ៉ាប់រង (ដុល្លារ) |
|---|---|
| មរណភាព/ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ | $១០,០០០ នឹងត្រូវទូទាត់ក្នុងករណីមរណភាព/ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ របស់កូនប្រុសលោក ដារ៉ា |
| អត្ថប្រយោជន៍ដល់កាលកំណត់បណ្ណសន្យារ៉ាប់រង | $១១,០០០ នឹងត្រូវផ្តល់ជូនក្នុងអំឡុងពេលនៃការសិក្សាសាកលវិទ្យាល័យរបស់កូនលោកដារ៉ា |

ដោយគាត់ជ្រើសរើសយកជម្រើសសាកលវិទ្យាល័យ កូនរបស់គាត់នឹងទទួលបានអត្ថប្រយោជន៍ការសិក្សាដែលត្រូវបានធានាចំនួន ១១០% នៃចំនួនទឹកប្រាក់ធានារ៉ាប់រង ដែលនឹងចាប់ផ្តើមនៅពេលកូនរបស់គាត់មានអាយុ ១៩ ឆ្នាំ៖

| អាយុអ្នកត្រូវបានធានា (ថ្ងៃកំណើតចុងក្រោយ) | អត្ថប្រយោជន៍កាសិក្សាដែលត្រូវបានធានា | អត្ថប្រយោជន៍សរុប |
|---|---|---|
| ១៩ | $២,០០០ | $១១,០០០ (១១០% នៃចំនួនទឹកប្រាក់ធានារ៉ាប់រង) |
| ២០ | $២,៥០០ | |
| ២១ | $៣,០០០ | |
| ២២ | $៣,៥០០ | |

ខិត្តប័ណ្ណនេះផ្តល់នូវព័ត៌មានបឋមអំពីផលិតផលប៉ុណ្ណោះ។ លោកអ្នកត្រូវអានបណ្ណសន្យារ៉ាប់រង នៃផលិតផលនេះ ដើម្បីជ្រាបពីព័ត៌មានលម្អិត ហើយស្វែងរកការប្រឹក្សាយោបល់ពីបុគ្គលិកផ្នែកលក់ធានារ៉ាប់រង របស់យើងខ្ញុំ មុននឹងសម្រេចចិត្តទិញផលិតផលនេះ។

## ករណីមិនធានា

### សម្រាប់ការទាមទារសំណងចំពោះមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

**រាល់ការទាមទារសំណងចំពោះ មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD) ទាំងឡាយណាដែលកើតឡើងដោយផ្ទាល់ ឬប្រយោលដោយមូលហេតុខាងក្រោម នឹងមិនត្រូវបានធានាឡើយ៖**

- ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមានវិបល្លាសក៏ដោយ ឬ
- ឆ្លងមេរោគហ៊ីវ (HIV) ឬជំងឺអេដស៍ (AIDS) ឬជំងឺផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងមេរោគហ៊ីវ (HIV) ឬជំងឺអេដស៍ (AIDS) ឬ
- ការប្រើប្រាស់ខុសច្បាប់ នូវថ្នាំណាកូទីគ (narcotics) ថ្នាំរំញោច (stimulants) ឬសារធាតុញៀនដទៃទៀត ឬ
- ទទួលទោសប្រហារជីវិតឬចូលរួមក្នុងសកម្មភាពខុសច្បាប់ឬប្រឆាំងនឹងការចាប់ខ្លួនរបស់អាជ្ញាធរ ឬសកម្មភាពលួចចេញពីពន្ធនាគារ ឬ
- សកម្មភាពខុសច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកទទួលផល ដែលរំលោភទៅនឹងបទបញ្ញត្តិនានា ដូចដែលបានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ឬ
- សង្គ្រាម(ទោះមានឬមិនមានការប្រកាសជាមុន)សង្គ្រាមស៊ីវិលឬជម្លោះប្រដាប់អាវុធផ្សេងៗ ឬ
- ការបង្កគ្រោះថ្នាក់ដោយខ្លួនឯង របស់អ្នកត្រូវបានធានារ៉ាប់រង/ម្ចាស់បណ្ណសន្យារ៉ាប់រង ទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមានវិបល្លាសក៏ដោយ ឬ
- ចូលរួមនៅក្នុងសកម្មភាពហោះហើរលើកលែងតែជាអ្នកដំណើរនៃអាកាសចរណ៍ស៊ីវិលដែលមានកាលវិភាគហោះហើរ ឬ
- បម្រើការងារក្នុងជួរយោធា ឬកងទ័ពជើងទឹកនៅក្នុងអំឡុងពេលដែលមានសង្គ្រាម (ទោះមាន ឬមិនមានការប្រកាសជាមុន) ឬនៅក្រោមបញ្ជានៃប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ។